# អ្វីជាមុខងារសុត្ថិភាព២ជាន់ ឬ 2FA ?

Two-Factor Authentication (2FA) គឺជាបំពាក់សុវត្ថិភាពបន្ថែមលើគណនីរបស់អ្នក ដោយមិនពឹងផ្អែកទាំងស្រុងតែលើពាក្យសម្ងាត់របស់អ្នក។ អ្នកអាចជ្រើសរើសយកការផ្ទៀងផ្ទាត់២ ក្នុងចំណោមជម្រើសពផ្សេងគ្នា ដោយទី១គឺការប្រើពាក្យសម្ងាត់ (អ្វីដែលអ្នកដឹង) និងទី២គឺជាការផ្ទៀងផ្ទាត់ជាមួយនឹងឧបករណ៍ដែលជាកម្មសិទ្ធិអ្នកដូចជា ទូរស័ព្ទរបស់អ្នកជាដើម (អ្វីដែលអ្នកមាន) ឬក៏អាចផ្ទៀងផ្ទាត់ដោយប្រើខ្ទៅដៃរបស់អ្នកជាដើម (អ្វីដែលជាអ្នក)។

ទោះបីជាអ្នកផ្សេងដឹងពាក្យសម្ងាត់របស់អ្នក ពួកគេក៏នៅមិនទាន់អាចចូលទៅគ្រប់គ្រងគណនីអ្នកបានដែរ ព្រោះ 2FA តម្រូវឱ្យពួកគេធ្វើការផ្ទៀងផ្ទាត់ម្តងទៀត ជាមួយឧបករណ៍ ឬខ្ទៅដៃរបស់អ្នក។






## អ្វីដែលអ្នកដឹង

សំដៅលើពាក្យសម្ងាត់របស់អ្នក។ នៅពេលដែលអ្នកចូលទៅកាន់គណនីណាមួយ គឺតម្រូវឱ្យអ្នកវាយបញ្ចូលពាក្យសម្ងាត់ឱ្យបានត្រឹមត្រូវដើម្បីបញ្ជាក់ថាអ្នកពិតជាម្ចាស់គណនីនោះប្រាកដមែន។

## អ្វីដែលអ្នកមាន

សំដៅលើអ្វីដែលជាកម្មសិទ្ធិរបស់អ្នក ដូចជាទូរស័ព្ទដៃ USBសុវត្ថិភាព (Security Key) កម្មវិធីនៅលើទូរស័ព្ទដៃ (Two-Factor Authentication App) របស់អ្នកជាដើម។ មធ្យោបាយពេញនិយមជាងគេ គឺការប្រើសារ SMS។ បន្ទាប់ពីវាយពាក្យ សម្ងាត់រួច អ្នកនៅមិនទាន់អាចចូល ទៅកាន់គណនីរបស់អ្នកនៅឡើយទេ គឺតម្រូវឱ្យអ្នកវាយលេខកូដដែលបានផ្ញើចូលទៅក្នុងទូរស័ព្ទដៃរបស់អ្នក ដើម្បីផ្ទៀងផ្ទាត់ម្តងទៀត។

## អ្វីដែលជាអ្នក

សំដៅលើខ្ទៅដៃ ឬប្រស្រីភ្នែក (Biometric) ជាដើម។ ខ្ទៅដៃត្រូវបានគេនិយមប្រើសម្រាប់ជាស្រទាប់ការពារបន្ថែមនៅឧបករណ៍ ឬគណនីណាមួយ ដើម្បីបញ្ជាក់ពីភាពជាម្ចាស់លើឧបករណ៍ ឬគណនីនោះ បន្ទាប់ពីវាយពាក្យសម្ងាត់រួច។